# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ១២៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ , ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៦៩ អនក្រ.បក, ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១** : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣.០០០ លានរៀល (បីពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ (ការទិញ) ជូនក្រសួងការពារជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

**មាត្រា២**: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ចំណាយលើពលទាហានរើសថ្មីចំនួន ១.៥០០ នាក់ ក្នុងឆ្នាំ ២០១១។

**មាត្រា៣**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**